ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...៣១២៥៥...អពដ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យដំណើរការ ការបង់ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ នៅធនាគារវឌ្ឍនៈ

ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈឱ្យកាន់តែមានគុណភាព ស័ក្តិសិទ្ធិ គួរឱ្យទុកចិត្ត រហ័ស ងាយស្រួល សមស្របទៅនឹងសេចក្តីត្រូវការរបស់អ្នកជាប់ពន្ធ នាពេលថ្មីៗនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារវឌ្ឍនៈ សម្រាប់ប្រតិបត្តិការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទ អនុវត្តនៅទូទាំងប្រទេស។

ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស អ្នកជាប់ពន្ធទាំងអស់មេត្តាជ្រាបថា ធនាគារវឌ្ឍនៈ បានត្រៀមលក្ខណៈរួចរាល់ និង<u>**ដាក់ឱ្យដំណើរការទទួលប្រាក់ពន្ធ-អាករគ្រប់ប្រភេទ ចាប់ពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ តទៅ**</u>។ ដូច្នេះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស អ្នកជាប់ពន្ធ អាចអញ្ជើញទៅបង់ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ នៅតាមបញ្ជរបង់ប្រាក់ពន្ធ (Counter) របស់ធនាគារវឌ្ឍនៈ តាមពេលវេលាបម្រើសេវាកម្ម ដូចខាងក្រោម÷

**១- សម្រាប់ការិយាល័យកណ្តាល រាជធានីភ្នំពេញ (អគារវឌ្ឍនៈកាពីតាល)**
- <u>**ថ្ងៃច័ន្ទ ដល់ថ្ងៃអាទិត្យ**</u>
- <u>**ម៉ោង៩ : ០០ ព្រឹក រហូតដល់ម៉ោង ១៨ : ៣០ ល្ងាច**</u>

**២- សម្រាប់បណ្តាសាខាធនាគារវឌ្ឍនៈ ទូទាំងព្រះរាជាណាចក្រកម្ពុជា**
- <u>**ថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ÷ ចាប់ពីម៉ោង ៨ : ០០ ព្រឹក រហូតដល់ម៉ោង ១៦ : ០០ ល្ងាច**</u>
- <u>**ថ្ងៃសៅរ៍ ÷ ចាប់ពីម៉ោង ៨: ០០ ព្រឹក រហូតដល់ម៉ោង ១១ : ៣០ ព្រឹក**</u>

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស អ្នកជាប់ពន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងអាចអញ្ជើញទៅបង់ប្រាក់ពន្ធនៅតាមទីកន្លែងនិងពេលវេលាដូចជម្រាបជូនខាងលើ ក្នុងករណីលោកឧកញ៉ា លោកជំទាវ លោក-លោកស្រី មានបំណងប្រើប្រាស់សេវាបង់ប្រាក់ពន្ធរបស់ធនាគារវឌ្ឍនៈ។

Collection by VCAT Professional Consultant

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ទំនាក់ទំនង ÷**
- អគ្គនាយកដ្ឋានពន្ធដារ ÷
  លោក **ហ៊ល ធីរិត** ទូរស័ព្ទលេខ ០១២ ៤៣៥ ១៥២
- ធនាគារវឌ្ឍនៈ ÷
  លោក **តុំ ពិសិដ្ឋ** ទូរស័ព្ទលេខ ០១២ ៤៧៤ ៤៤៤